រដ្ឋសភា
ចូល លេខ.......... ថ្ងៃទី.......... ឆ្នាំ.......... ម៉ោង..........
បញ្ជូនទៅ..........

# ព្រះរាជក្រម

នស/រកម/១០២១/០១៧

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានត្ថមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការប្រកួតប្រជែង ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០២១ នាសម័យប្រជុំរដ្ឋសភាលើកទី៦ នីតិកាលទី៦ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២១ នាសម័យប្រជុំពេញអង្គលើកទី៧ នីតិកាលទី៤ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *
ព្រះរាជវាំង

# ច្បាប់
# ស្តីពី
# ការប្រកួតប្រជែង

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

# ជំពូកទី១
# បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

ច្បាប់នេះកំណត់អំពីសកម្មភាពដែលរារាំង រឹតត្បិត ឬបង្ខូចដល់ការប្រកួតប្រជែង ព្រមទាំងបង្កើតនិងកំណត់សមត្ថកិច្ចរបស់គណៈកម្មាធិការប្រកួតប្រជែងកម្ពុជា ក្នុងគោលបំណងដើម្បីលើកទឹកចិត្តឱ្យមានទំនាក់ទំនងធុរកិច្ចដោយស្មើភាពនិងស្មោះត្រង់ បង្កើនប្រសិទ្ធភាពសេដ្ឋកិច្ច ជំរុញឱ្យមានការបង្កើតធុរកិច្ចថ្មីៗ និងជួយអ្នកប្រើប្រាស់ឱ្យទទួលបានទំនិញនិងសេវាមានគុណភាពខ្ពស់ ថ្លៃទាប សម្បូរបែប និងមានជម្រើសច្រើន។

**មាត្រា២ .-**

ច្បាប់នេះមានវិសាលភាពអនុវត្តចំពោះបុគ្គលធ្វើសកម្មភាពធុរកិច្ច ឬធ្វើសកម្មភាពគាំទ្រដល់ធុរកិច្ចពាក់ព័ន្ធនឹងការរារាំង រឹតត្បិត ឬបង្ខូចដល់ការប្រកួតប្រជែងគួរឱ្យកត់សម្គាល់ក្នុងទីផ្សារនៃព្រះរាជាណាចក្រកម្ពុជា ទោះបីសកម្មភាពនោះមានប្រភពនៅក្នុងឬក្រៅប្រទេសក៏ដោយ។

**មាត្រា៣ .-**

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងច្បាប់នេះមាននិយមន័យដូចខាងក្រោម៖

១- ការប្រកួតប្រជែង សំដៅដល់សកម្មភាពរបស់បុគ្គលធ្វើធុរកិច្ចនៅក្នុងទីផ្សារ ដើម្បីដណ្តើមយកអតិថិជនឱ្យបានច្រើនក្នុងការប្រើប្រាស់នូវទំនិញឬសេវារបស់ខ្លួន ទទួលបាននូវចំណែកទីផ្សារច្រើន និងជំហរឧត្តមភាពលើទីផ្សារ។

២- ការព្រមព្រៀង សំដៅដល់គ្រប់ទម្រង់នៃកិច្ចសន្យា កិច្ចព្រមព្រៀង ការរៀបចំឬការយល់គ្នារវាងបុគ្គលនិងបុគ្គល ហើយអាចធ្វើឡើងជាលាយលក្ខណ៍អក្សរ ដោយផ្ទាល់មាត់ ដោយតុណ្ហីភាព ឬដោយរួមបញ្ចូលនូវការសម្របសម្រួលដោយបុគ្គលដែលមានទំនាក់ទំនងដោយផ្ទាល់ឬមិនផ្ទាល់ ហើយដែលកម្មវត្ថុឬអានុភាពនៃទំនាក់ទំនងនោះ៖

ក-បណ្តាលឱ្យមានឥទ្ធិពលលើអំពើរបស់បុគ្គលមួយឬច្រើននៅលើទីផ្សារ ឬ

ខ-បង្ហាញពីអំពើឬសកម្មភាពដែលបុគ្គលណាមួយបានសម្រេចរួចហើយ ឬមានគោលបំណងនឹងយកមកអនុវត្តនៅក្នុងទីផ្សារ។

៣- ការរួមបញ្ចូលគ្នានៃធុរកិច្ច សំដៅដល់៖

- ការទទួលបាន ឬទិញនូវសិទ្ធិគ្រប់គ្រងឬសិទ្ធិបោះឆ្នោត តាមរយៈការទិញភាគហ៊ុនឬទ្រព្យសម្បត្តិដោយបុគ្គលណាមួយពីបុគ្គលផ្សេងទៀត ឬ
- ការរំលាយបញ្ចូលគ្នារវាងបុគ្គលពីរឬច្រើន ដើម្បីក្លាយជាម្ចាស់រួមគ្នាលើនីតិបុគ្គលដែលមានស្រាប់ ឬនីតិបុគ្គលថ្មី។

៤- ទំនាស់ផលប្រយោជន៍ សំដៅដល់ផលប្រយោជន៍ជាទឹកប្រាក់ ផលប្រយោជន៍គ្រួសារ ឬផលប្រយោជន៍ផ្ទាល់ខ្លួន ដែលអាចមានឥទ្ធិពលលើទង្វើរបស់បុគ្គលណាមួយក្នុងការបំពេញភារកិច្ចផ្លូវការរបស់ខ្លួន។

៥- អគ្គនាយកដ្ឋាន សំដៅដល់អគ្គនាយកដ្ឋានដែលទទួលបន្ទុកកិច្ចការប្រកួតប្រជែង។

៦- ជំហរឧត្តមភាពលើទីផ្សារ សំដៅដល់ស្ថានភាពដែលបុគ្គលណាមួយមានអំណាចលើទីផ្សារដែល [illegible]ដោយគ្មានការរាំងពីគូប្រកួតប្រជែងផ្សេងទៀត។

៧. មធ្យោបាយចាំបាច់ សំដៅដល់ហេដ្ឋារចនាសម្ព័ន្ធ ឬធនធាននានាដែលមិនអាចបង្កើតជាន់គ្នាបាននិងបើគ្មានមធ្យោបាយចាំបាច់នោះទេ គូប្រកួតប្រជែងនានាមិនអាចផ្គត់ផ្គង់ទំនិញឬសេវាឱ្យទៅអតិថិជនដោយសមស្របបានឡើយ។

៨. **ការព្រមព្រៀងខ្សែដេក** សំដៅដល់ការព្រមព្រៀងរវាងបុគ្គលដែលធ្វើប្រតិបត្តិការឬអាចធ្វើប្រតិបត្តិការនៅក្នុងកម្រិតស្មើគ្នានៃខ្សែច្រវាក់ផលិតកម្មនិងចែកចាយ។

៩. **ការព្រមព្រៀងខ្សែឈរ** សំដៅដល់ការព្រមព្រៀងរវាងបុគ្គលដែលធ្វើប្រតិបត្តិការឬដែលអាចធ្វើប្រតិបត្តិការនៅក្នុងកម្រិតខុសៗគ្នានៅក្នុងខ្សែច្រវាក់ផលិតកម្មនិងចែកចាយ។

១០. **ទីផ្សារ** សំដៅដល់ទីផ្សារទំនិញឬសេវាដែលកំពុងប្រកួតប្រជែង។

១១. **បុគ្គល** សំដៅដល់រូបវន្តបុគ្គលឬនីតិបុគ្គលដែលបង្កើតឬរៀបចំឡើងយ៉ាងត្រឹមត្រូវតាមច្បាប់ជាធរមាន ទោះបីដើម្បីរកប្រាក់ចំណេញឬមិនរកប្រាក់ចំណេញក្តី បានចុះបញ្ជីឬមិនបានចុះបញ្ជីក្តី។

១២. **បុគ្គលរាយការណ៍** សំដៅដល់បុគ្គលទាំងឡាយណាដែលស្ម័គ្រចិត្តផ្តល់ព័ត៌មានអំពីសកម្មភាពដែលអាចបំពានច្បាប់ស្តីពីការប្រកួតប្រជែងមកគ.ប.ក. ទោះសកម្មភាពនោះបានកើតឡើងហើយ ឬកំពុងកើតឡើង ឬបម្រុងនឹងកើតឡើង។

១៣. **គូប្រកួតប្រជែង** សំដៅដល់បុគ្គលដែលកំពុងប្រកួតប្រជែងនៅក្នុងទីផ្សារណាមួយឬបុគ្គលដទៃទៀតដែលមានសក្តានុពលអាចនឹងចូលរួមប្រកួតប្រជែងក្នុងទីផ្សារ។

១៤. **រារាំង រឹតត្បិត ឬបង្ខូចដល់ការប្រកួតប្រជែងគួរឱ្យកត់សម្គាល់** សំដៅដល់សកម្មភាពដែលមានទំហំឬកម្រិតនៃការប៉ះពាល់ដល់ការប្រកួតប្រជែងលើទំនិញឬសេវា ដែលត្រូវបានកំណត់ដោយគ.ប.ក. ដោយផ្អែកលើលទ្ធផលពីការវិភាគលើកត្តាសេដ្ឋកិច្ចឬលើកត្តាផ្សេងៗទៀត។

១៥. **ធុរកិច្ច** សំដៅដល់សកម្មភាពដែល៖

- ក. ទំនិញឬសេវាត្រូវបានទទួល ឬផ្គត់ផ្គង់ ឬដែលសិទ្ធិប្រត្យក្សលើអចលនទ្រព្យត្រូវបានទទួល ឬចាត់ចែង ឬ
- ខ. បានធ្វើឡើងតាមវិធីដែលមានការរៀបចំនិងមានភាពច្បាស់លាស់ ឬ
- គ. បុគ្គលធ្វើសកម្មភាពនោះមានគោលបំណងរកប្រាក់ចំណេញទោះបីជាសកម្មភាពដែលបានធ្វើដោយបុគ្គលនោះជាសកម្មភាពចម្បង ឬបន្ទាប់បន្សំ ឬមិនធ្វើជាប្រចាំក៏ដោយ។

១៦. **បញ្ញត្តិករមានសមត្ថកិច្ច** សំដៅដល់ក្រសួង ស្ថាប័នណាមួយដែលមានមុខងារនិងតួនាទីពាក់ព័ន្ធនឹងកិច្ចការប្រកួតប្រជែងក្រោមការទទួលខុសត្រូវរបស់ខ្លួន។

## ជំពូកទី២
## ស្ថាប័នមានសមត្ថកិច្ច

**មាត្រា៤.-**

ត្រូវបានបង្កើតគណៈកម្មាធិការប្រកួតប្រជែងកម្ពុជា ដែលសរសេរជាអក្សរកាត់ថា គ.ប.ក. ដឹកនាំដោយរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មនិងមានការចូលរួមពីក្រសួង ស្ថាប័នពាក់ព័ន្ធ ដោយមានអគ្គនាយកដ្ឋានដែលទទួលបន្ទុកកិច្ចការប្រកួតប្រជែងជាសេនាធិការ ដើម្បីបំពេញភារកិច្ចនានាពាក់ព័ន្ធនឹងកិច្ចការប្រកួតប្រជែងស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់គ.ប.ក. ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា៥ ._**

គ.ប.ក.ត្រូវដឹកនាំដោយប្រធាន១(មួយ)រូប ដែលជារដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងមានអនុប្រធាន និងសមាជិកមួយចំនួនមកពីក្រសួង ស្ថាប័នពាក់ព័ន្ធតាមការចាំបាច់។

គ.ប.ក.ត្រូវមានសមាជិកដែលជាបុគ្គលឯករាជ្យផ្សេងទៀតដែលមានអាណត្តិ៥(ប្រាំ)ឆ្នាំ និងមានសមាសភាពដូចខាងក្រោម៖

- អតីតចៅក្រម ១រូប
- បុគ្គលមានចំណេះដឹងនិងបទពិសោធផ្នែកច្បាប់ ២រូប
- បុគ្គលមានចំណេះដឹងនិងបទពិសោធផ្នែកសេដ្ឋកិច្ច ២រូប។

នីតិវិធីនៃការជ្រើសរើសអតីតចៅក្រម បុគ្គលមានចំណេះដឹងនិងបទពិសោធផ្នែកច្បាប់ និងបុគ្គលមានចំណេះដឹងនិងបទពិសោធផ្នែកសេដ្ឋកិច្ច ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម។

សមាសភាពជាក់ស្តែងរបស់គ.ប.ក. ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

**មាត្រា៦ ._**

គ.ប.ក.មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

១. រៀបចំគោលនយោបាយនិងផែនការយុទ្ធសាស្ត្រដែលទាក់ទងដល់ការប្រកួតប្រជែង។

២. ផ្តល់យោបល់លើសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្តទាំងឡាយដែលពាក់ព័ន្ធដល់ការប្រកួតប្រជែងជូនរាជរដ្ឋាភិបាល។

៣. ស្នើសុំរាជរដ្ឋាភិបាលធ្វើការកែសម្រួលឬវិសោធនកម្មលើលិខិតបទដ្ឋានគតិយុត្តជាតិនិងអន្តរជាតិដែលប៉ះពាល់ដល់ការប្រកួតប្រជែង។

៤. ចេញសេចក្តីសម្រេច ចេញវិធានការផ្អាកឬឃាត់ទុកជាបណ្តោះអាសន្ន និងធ្វើការដាកពិន័យជាប្រាក់។

៥. បង្កើតបែបបទនិងនីតិវិធីនៃការគណនាប្រាក់ដាកពិន័យ។

៦. បង្កើតវិធានទាក់ទងនឹងទំនាស់ផលប្រយោជន៍របស់សមាជិកគ.ប.ក.។

៧. រៀបចំលក្ខខណ្ឌនិងនីតិវិធីអំពីការរួមបញ្ចូលគ្នានៃធុរកិច្ច។

៨. រៀបចំលក្ខខណ្ឌនិងនីតិវិធីនៃការផ្តល់ការអនុញ្ញាតចំពោះការព្រមព្រៀងឬសកម្មភាពណាមួយពាក់ព័ន្ធនឹងការប្រកួតប្រជែង។

៩. រៀបចំលក្ខខណ្ឌនិងនីតិវិធីនៃការផ្តល់ការអនុញ្ញាតជាសមូហភាពចំពោះការព្រមព្រៀងឬសកម្មភាពណាមួយពាក់ព័ន្ធនឹងការប្រកួតប្រជែង។

១០. រៀបចំលក្ខខណ្ឌនិងនីតិវិធីអំពីគោលការណ៍អនុគ្រោះលើការដាកពិន័យជាប្រាក់។

១១. ធ្វើកិច្ចសហប្រតិបត្តិការជាមួយស្ថាប័នឬបញ្ញត្តិករមានសមត្ថកិច្ចជាតិ រដ្ឋបរទេស និងអន្តរជាតិពាក់ព័ន្ធនឹងការប្រកួតប្រជែង។

១២. ទទួលពាក្យបណ្តឹង។

១៣. បង្កើតបទប្បញ្ញត្តិនិងវិធានផ្សេងៗទៀត ដែលជាសមត្ថកិច្ចរបស់គ.ប.ក. ពាក់ព័ន្ធនឹងការប្រកួតប្រជែង។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

# ជំពូកទី៣
# ការរារាំង រឹតត្បិត ឬបង្ខូចដល់ការប្រកួតប្រជែង
## ផ្នែកទី១
## ការព្រមព្រៀងដែលរារាំង រឹតត្បិត ឬបង្ខូចដល់ការប្រកួតប្រជែង

**មាត្រា៧ .-**

ត្រូវបានហាមឃាត់ការបង្កើតនិងការអនុវត្តការព្រមព្រៀងខ្សែដេកដោយផ្ទាល់ឬប្រយោលដែលប៉ះពាល់ដល់ការប្រកួតប្រជែងដូចខាងក្រោម៖

១- ការព្រមព្រៀងការកំណត់ថ្លៃ គ្រប់គ្រងថ្លៃ រក្សាថ្លៃ ចំពោះទំនិញឬសេវា។

២- ការព្រមព្រៀងការរារាំង រឹតត្បិត កម្រិត៖

- បរិមាណទំនិញឬសេវាដែលមានសម្រាប់លក់
- ប្រភេទទំនិញឬសេវាដែលមានសម្រាប់លក់
- ការអភិវឌ្ឍទំនិញឬសេវាថ្មី។

៣- ការព្រមព្រៀងការបែងចែកតំបន់ភូមិសាស្ត្ររវាងគូប្រកួតប្រជែង។

៤- ការព្រមព្រៀងការបែងចែកអតិថិជនរវាងគូប្រកួតប្រជែង។

៥- ការដេញថ្លៃទាំងឡាយណាដែលមានទំនោរទៅរកតែអ្នកដេញថ្លៃតែមួយ ដើម្បីទទួលបានកិច្ចសន្យាដេញថ្លៃនោះសម្រាប់ការធ្វើលទ្ធកម្មឯកជន។

**មាត្រា៨ .-**

ត្រូវបានហាមឃាត់ការព្រមព្រៀងខ្សែឈរ ដែលតម្រូវឱ្យអ្នកទិញលក់បន្តនូវទំនិញឬសេវាដែលបានទិញក្នុងតម្លៃអប្បបរមាមួយដោយផ្ទាល់ឬប្រយោល ឬតម្រូវឱ្យអ្នកទិញទទួលយកនូវលក្ខខណ្ឌរួមណាមួយដែលត្រូវបានកំណត់ដោយបុគ្គលនោះ។

ត្រូវបានហាមឃាត់ការបង្កើតនិងការអនុវត្តការព្រមព្រៀងខ្សែឈរដែលមានឬអាចមានកម្មវត្ថុ ឬអានុភាពរារាំង រឹតត្បិត ឬបង្ខូចដល់ការប្រកួតប្រជែងគួរឱ្យកត់សម្គាល់នៅក្នុងទីផ្សារដូចខាងក្រោម៖

១- ការតម្រូវឱ្យអ្នកទិញលក់បន្តនូវទំនិញឬសេវានានា ដែលបានទិញតែនៅក្នុងទីតាំងភូមិសាស្ត្រកំណត់ណាមួយ។

២- ការតម្រូវឱ្យអ្នកទិញលក់បន្តនូវទំនិញឬសេវានានា ដែលបានទិញទៅឱ្យអតិថិជនជាក់លាក់ណាមួយឬប្រភេទអតិថិជនជាក់លាក់ណាមួយ។

៣- ការតម្រូវឱ្យអ្នកទិញទទួលយកនូវលក្ខខណ្ឌទាំងអស់ឬស្ទើរតែទាំងអស់សម្រាប់ការទិញទំនិញឬសេវាជាក់លាក់ណាមួយពីអ្នកលក់នោះតែមួយប៉ុណ្ណោះ។

៤- ការរារាំងអ្នកលក់ពីការលក់ទំនិញឬសេវាទៅឱ្យអ្នកទិញផ្សេងទៀត។

៥- ការតម្រូវឱ្យអ្នកទិញទិញគួបទំនិញឬសេវាដែលមិនពាក់ព័ន្ធដទៃទៀត បន្ថែមពីលើទំនិញឬសេវាដែលអ្នកទិញចង់ទិញ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

## ផ្នែកទី២
## សកម្មភាពបំពានដោយប្រើជំហរឧត្តមភាពលើទីផ្សារ

**មាត្រា៩ .-**

ត្រូវបានហាមឃាត់ ចំពោះសកម្មភាពបំពានដោយបុគ្គលមានជំហរឧត្តមភាពលើទីផ្សារ ប្រសិនបើសកម្មភាពនោះបានធ្វើដោយបុគ្គលណាមួយដែលមានជំហរឧត្តមភាពលើទីផ្សារ ហើយសកម្មភាពនោះមានកម្មវត្ថុ ឬអានុភាពរារាំង រឹតត្បិត ឬបង្ខូចដល់ការប្រកួតប្រជែងគួរឱ្យកត់សម្គាល់នៅក្នុងទីផ្សារណាមួយដូចខាងក្រោម៖

១- ការតម្រូវឬការបញ្ចុះបញ្ចូលឱ្យអ្នកផ្គត់ផ្គង់ឬអតិថិជនមិនឱ្យធ្វើអាជីវកម្មជាមួយគូប្រកួតប្រជែងណាមួយ។

២- ការបដិសេធមិនព្រមផ្គត់ផ្គង់ទំនិញឬសេវាឱ្យគូប្រកួតប្រជែងណាមួយ។

៣- ការលក់ទំនិញឬសេវាក្នុងលក្ខខណ្ឌដែលអ្នកទិញត្រូវទិញទំនិញឬសេវាផ្សេងៗ ដោយឡែកដែលមិនទាក់ទងនឹងកម្មវត្ថុនៃកិច្ចសន្យា។

៤- ការលក់ទំនិញឬសេវាទាបជាងថ្លៃដើមផលិត។

៥- ការបដិសេធមិនឱ្យគូប្រកួតប្រជែងណាមួយប្រើប្រាស់មធ្យោបាយចាំបាច់។

**មាត្រា១០ .-**

បុគ្គលដែលមានជំហរឧត្តមភាពលើទីផ្សារអាចធ្វើសកម្មភាពដូចមានកំណត់ក្នុងមាត្រា៩នៃច្បាប់នេះមិនត្រូវបានចាត់ទុកជាសកម្មភាពបំពានឡើយ ប្រសិនបើគ.ប.ក. យល់ឃើញថាបុគ្គលនោះបានបំពេញនូវលក្ខខណ្ឌទាំងពីរដូចខាងក្រោម៖

១- មានមូលហេតុសមស្របក្នុងការធ្វើសកម្មភាពនោះ ដើម្បីផលប្រយោជន៍ធុរកិច្ចដោយស្របច្បាប់។

២- សកម្មភាពនោះមិនរារាំង រឹតត្បិត ឬបង្ខូចដល់ការប្រកួតប្រជែងគួរឱ្យកត់សម្គាល់នៅក្នុងទីផ្សារទេ។

## ផ្នែកទី៣
## ការរួមបញ្ចូលគ្នានៃធុរកិច្ច

**មាត្រា១១ .-**

ការរួមបញ្ចូលគ្នានៃធុរកិច្ចទាំងឡាយណាដែលមាន ឬអាចមានកម្មវត្ថុ ឬអានុភាពរារាំង រឹតត្បិត ឬបង្ខូចដល់ការប្រកួតប្រជែងគួរឱ្យកត់សម្គាល់នៅក្នុងទីផ្សារ ត្រូវបានហាមឃាត់។

ការរួមបញ្ចូលគ្នានៃធុរកិច្ចជាកម្មវត្ថុនៃការត្រួតពិនិត្យ ការតាមដាន និងការវាយតម្លៃលើផលប៉ះពាល់ចំពោះការប្រកួតប្រជែងដូចមានចែងក្នុងកថាខណ្ឌខាងលើ ត្រូវធ្វើឡើងដោយគ.ប.ក.។

លក្ខខណ្ឌនិងនីតិវិធីអំពីការរួមបញ្ចូលគ្នានៃធុរកិច្ចត្រូវកំណត់ដោយអនុក្រឹត្យ។

## ផ្នែកទី៤
## ការលើកលែងចំពោះការព្រមព្រៀងខ្សែដេក ខ្សែឈរ សកម្មភាពបំពានដោយប្រើជំហរឧត្តមភាពលើទីផ្សារនិងការរួមបញ្ចូលគ្នានៃធុរកិច្ច

**មាត្រា១២ .-**

ការព្រមព្រៀងឬសកម្មភាពដែលត្រូវបានហាមឃាត់ដូចមានចែងក្នុងមាត្រា៧ មាត្រា៨ មាត្រា៩ និងមាត្រា[illegible]នៃច្បាប់នេះ អាចត្រូវបានលើកលែង ប្រសិនបើការព្រមព្រៀងឬសកម្មភាពទាំងនោះបំពេញតាមលក្ខខណ្ឌ[illegible]នដូចខាងក្រោម៖

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

១- ផ្តល់នូវអត្ថប្រយោជន៍សំខាន់ដោយផ្ទាល់ដល់បច្ចេកវិទ្យា សង្គម ឬសេដ្ឋកិច្ច។

២- អត្ថប្រយោជន៍ទាំងនោះអាចនឹងមិនកើតមានឡើយ ប្រសិនបើគ្មានការព្រមព្រៀងឬសកម្មភាពដែលត្រូវបានហាមឃាត់ទាំងនោះទេ។

៣- អត្ថប្រយោជន៍ទាំងនោះមានច្រើនជាងផលប៉ះពាល់ដែលកើតពីការរារាំង រឹតត្បិត ឬបង្ខូចដល់ការប្រកួតប្រជែងគួរឱ្យកត់សម្គាល់។

៤- មិនលុបបំបាត់ការប្រកួតប្រជែងលើផ្នែកសំខាន់ៗណាមួយរបស់ទំនិញឬសេវា។

**មាត្រា១៣.-**

បុគ្គលដែលយល់ឃើញថា ការព្រមព្រៀងឬសកម្មភាពណាមួយដែលអាចនឹងបំពានច្បាប់ដូចមានចែងក្នុងមាត្រា៧ មាត្រា៨ មាត្រា៩ និងមាត្រា១១នៃច្បាប់នេះ អាចស្នើសុំការអនុញ្ញាតពីគ.ប.ក. មុនពេលធ្វើការព្រមព្រៀងឬធ្វើសកម្មភាពនោះ។ គ.ប.ក.អាចផ្តល់ការអនុញ្ញាតបាន ប្រសិនបើការព្រមព្រៀងឬសកម្មភាពនោះមិនបានបំពានមាត្រា៧ មាត្រា៨ មាត្រា៩ និងមាត្រា១១នៃច្បាប់នេះទេ។

ប្រសិនបើការព្រមព្រៀងឬសកម្មភាពណាមួយបានបំពានមាត្រា៧ មាត្រា៨ មាត្រា៩ និងមាត្រា១១នៃច្បាប់នេះ បុគ្គលនោះមានបំណងស្នើសុំការលើកលែងដូចមានចែងក្នុងមាត្រា១២នៃច្បាប់នេះ ត្រូវស្នើសុំការលើកលែងមកគ.ប.ក. ដោយភ្ជាប់នូវភស្តុតាងដែលអាចបញ្ជាក់ពីការបំពេញគ្រប់លក្ខខណ្ឌដូចមានកំណត់ក្នុងមាត្រា១២នៃច្បាប់នេះ។ គ.ប.ក.ផ្តល់ការអនុញ្ញាតបានលុះត្រាណាតែការព្រមព្រៀងឬសកម្មភាពនោះបានបំពេញតាមលក្ខខណ្ឌដូចមានចែងក្នុងមាត្រា១២នៃច្បាប់នេះ។ នៅពេលផ្តល់ការអនុញ្ញាត គ.ប.ក.ត្រូវបញ្ជាក់អំពីសុពលភាពនៃការអនុញ្ញាតនោះ។

លក្ខខណ្ឌនិងនីតិវិធីនៃការស្នើសុំការអនុញ្ញាតនេះ ត្រូវកំណត់ដោយគ.ប.ក.។

ការសុំការអនុញ្ញាតលើកលែងត្រូវបង់កម្រៃសេវា ដែលកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម។

**មាត្រា១៤.-**

ប្រសិនបើគ.ប.ក.យល់ឃើញថា ប្រភេទនៃការព្រមព្រៀងឬសកម្មភាពលើទំនិញឬសេវាជាក់លាក់ណាមួយបានបំពេញតាមលក្ខខណ្ឌដូចមានចែងក្នុងមាត្រា១២នៃច្បាប់នេះ នោះ គ.ប.ក.អាចផ្តល់ការអនុញ្ញាតជាសមូហភាពលើប្រភេទនៃការព្រមព្រៀងឬសកម្មភាពទាំងនោះ។ នៅពេលផ្តល់ការអនុញ្ញាត គ.ប.ក.អាចបញ្ជាក់អំពីសុពលភាពនៃការអនុញ្ញាតនោះ។

លក្ខខណ្ឌនិងនីតិវិធីអំពីការអនុញ្ញាតជាសមូហភាពលើប្រភេទនៃការព្រមព្រៀងឬសកម្មភាពណាមួយត្រូវកំណត់ដោយគ.ប.ក.។

## ផ្នែកទី៥
## គោលការណ៍អនុគ្រោះ

**មាត្រា១៥.-**

បុគ្គលចូលរួមឬផ្តល់ជំនួយក្នុងការព្រមព្រៀងខ្សែដេកបំពានច្បាប់ អាចទទួលបានគោលការណ៍អនុគ្រោះដែលកំណត់ដោយគ.ប.ក. ចំពោះការលើកលែងលើការដាក់ពិន័យជាប្រាក់ ក្នុងករណីដែលបុគ្គលនេះបានផ្តល់ភស្តុតាងឬព័ត៌មានសំខាន់ៗពាក់ព័ន្ធដល់ការព្រមព្រៀងខ្សែដេកបំពានច្បាប់។ គោលការណ៍អនុគ្រោះចំពោះការលើកលែងលើការដាក់ពិន័យជាប្រាក់ត្រូវបន្តផ្តល់ទៅឱ្យបុគ្គលនោះ ទោះបីមានបណ្តឹងតវ៉ាលើសេចក្តីសម្រេចរបស់គ.ប.ក.។

លក្ខខណ្ឌនិងនីតិវិធីនៃការកំណត់គោលការណ៍អនុគ្រោះត្រូវកំណត់ដោយគ.ប.ក.។

# ជំពូកទី៤
# នីតិវិធីនៃការប្តឹងនិងការស៊ើបអង្កេត

**មាត្រា១៦ .-**

គ.ប.ក.មានសមត្ថកិច្ចទទួលពាក្យបណ្តឹងតាមរយៈ៖

១- ការផ្តួចផ្តើមរបស់គ.ប.ក. ខ្លួនឯង ឬ

២- បណ្តឹងពីបញ្ញត្តិករមានសមត្ថកិច្ចណាមួយ ឬ

៣- បណ្តឹងពីបុគ្គលផ្សេងទៀតក្រៅពីបញ្ញត្តិករមានសមត្ថកិច្ច។

**មាត្រា១៧ .-**

មន្ត្រីស៊ើបអង្កេតត្រូវជ្រើសចេញពីអគ្គនាយកដ្ឋានទទួលបន្ទុកកិច្ចការប្រកួតប្រជែង តាមប្រកាសរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ដើម្បីត្រួតពិនិត្យ ស្រាវជ្រាវ ប្រមូលទិន្នន័យ និងសាកសួរបុគ្គលពាក់ព័ន្ធឱ្យផ្តល់ព័ត៌មាន ឯកសារ ឬវត្ថុផ្សេងៗ សម្រាប់ធ្វើការវាយតម្លៃសកម្មភាពប្រកួតប្រជែងលើទីផ្សារនិងស្វែងរករាល់បទល្មើសដែលស្ថិតនៅក្រោមច្បាប់នេះ ព្រមទាំងអនុវត្តវិធានការផ្អាកជាបណ្តោះអាសន្នចំពោះការព្រមព្រៀង ឬសកម្មភាពដែលរារាំង រឹតត្បិត ឬបង្ខូចដល់ការប្រកួតប្រជែងលើទីផ្សារដែលចេញដោយគ.ប.ក.។

ក្នុងករណីចាំបាច់ គ.ប.ក.អាចស្នើសុំកិច្ចសហការពីស្ថាប័នឬបញ្ញត្តិករមានសមត្ថកិច្ច តាមសំណើរបស់មន្ត្រីស៊ើបអង្កេត ហើយស្ថាប័នឬបញ្ញត្តិករនោះ ត្រូវផ្តល់កិច្ចសហការតាមការស្នើសុំនេះ។

**មាត្រា១៨ .-**

មន្ត្រីស៊ើបអង្កេតទទួលនីតិសម្បទាជានគរបាលយុត្តិធម៌ឱ្យពិនិត្យបទល្មើសដែលមានចែងក្នុងច្បាប់នេះ ដោយអនុវត្តស្របតាមបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ។

បែបបទនិងនីតិវិធីនៃការផ្តល់នីតិសម្បទាចំពោះមន្ត្រីស៊ើបអង្កេតត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌និងរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម។

**មាត្រា១៩ .-**

មន្ត្រីស៊ើបអង្កេតមានសិទ្ធិឆែកឆេរ ចាប់យកវត្ថុតាង កោះហៅបុគ្គលពាក់ព័ន្ធ និងបំពេញកិច្ចនីតិវិធីដទៃទៀតដោយអនុវត្តស្របតាមបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ។

មន្ត្រីស៊ើបអង្កេតមានសិទ្ធិស្នើសុំជំនួយពីរដ្ឋបាលថ្នាក់ក្រោមជាតិនិងអង្គភាពប្រដាប់អាវុធ ឬអាជ្ញាធរមានសមត្ថកិច្ចដែលពាក់ព័ន្ធផ្សេងទៀត ដើម្បីចូលរួមបង្ក្រាបបទល្មើសដែលមានចែងក្នុងច្បាប់នេះ។

មន្ត្រីស៊ើបអង្កេតមិនអាចផ្តើមធ្វើការឆែកឆេរមុនម៉ោង៦(ប្រាំមួយ)ព្រឹក និងក្រោយម៉ោង១៨(ដប់ប្រាំបី) ឡើយ លើកលែងតែមានកិច្ចសហការពីស្ថាប័នប្រកួតប្រជែងនៃប្រទេសណាមួយស្នើសុំ នោះមន្ត្រីស៊ើបអង្កេតត្រូវរាយការណ៍សុំយោបល់ពីព្រះរាជអាជ្ញា។

**មាត្រា២០ .-**

មន្ត្រីស៊ើបអង្កេតអាចសាកសួរសាក្សីណាមួយបាន ប្រសិនបើមន្ត្រីស៊ើបអង្កេតយល់ឃើញថា សក្ខីកម្មរបស់សាក្សីអាចមានប្រយោជន៍ដល់ការស៊ើបអង្កេត។



ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

ក្នុងករណីសាក្សីណាមួយបដិសេធមិនចូលខ្លួនដោយគ្មានមូលហេតុ ធ្វើឱ្យប៉ះពាល់ដល់ដំណើរការស៊ើបអង្កេតស្វែងរកបទល្មើស មន្ត្រីស៊ើបអង្កេតអាចស្នើសុំទៅព្រះរាជអាជ្ញាមានសមត្ថកិច្ចបញ្ជាឱ្យសាក្សីរូបនោះចូលខ្លួនផ្តល់ចម្លើយចំពោះមុខមន្ត្រីស៊ើបអង្កេត។

**មាត្រា២១.-**

បុគ្គលរាយការណ៍ដោយសុចរិតត្រូវទទួលបាន៖

១- ការរក្សាការសម្ងាត់នូវអត្តសញ្ញាណដូចមានចែងក្នុងមាត្រា២២នៃច្បាប់នេះ។

២- ការការពារសន្តិសុខក្នុងករណីចាំបាច់។

៣- ការរួចផុតពីការទទួលខុសត្រូវផ្នែករដ្ឋប្បវេណី ឬព្រហ្មទណ្ឌ ឬទណ្ឌកម្មខាងវិជ្ជាជីវៈ ប្រសិនបើការទទួលខុសត្រូវនោះ កើតឡើងដោយសារការផ្តល់ឬបើកចំហរព័ត៌មានសម្ងាត់មកគ.ប.ក.។

ការទទួលបានខាងលើ ត្រូវបានផ្តល់ជូនដល់បុគ្គលរាយការណ៍ដោយសុចរិត បើទោះបីជាការរាយការណ៍នោះមិនអាចឈានដល់ការរកឃើញពីការបំពានច្បាប់នេះក៏ដោយ។

ក្នុងករណីដែលបុគ្គលរាយការណ៍ធ្វើឱ្យបែកធ្លាយនូវព័ត៌មានសម្ងាត់ ឬបានរាយការណ៍ដោយទុច្ចរិតនូវព័ត៌មានមិនពិត បុគ្គលរាយការណ៍នោះមិនត្រូវទទួលបានការការពារឡើយ លើកលែងតែមានការសម្រេចផ្សេងដោយគ.ប.ក.។

**មាត្រា២២.-**

ព័ត៌មានដែលមានចរិតលក្ខណៈជាការសម្ងាត់រួមមាន ព័ត៌មានសម្ងាត់ដែលទាក់ទងនឹងសកម្មភាពធុរកិច្ចរបស់បុគ្គល ព័ត៌មានសម្ងាត់ដែលទាក់ទងនឹងអត្តសញ្ញាណរបស់បុគ្គលរាយការណ៍ ព័ត៌មានអំពីអត្តសញ្ញាណរបស់បុគ្គលដែលត្រូវស៊ើបអង្កេត ព័ត៌មានដែលប្រមូលបានពីការស៊ើបអង្កេត និងព័ត៌មានដទៃទៀតដែលកំណត់ដោយគ.ប.ក.។

ព័ត៌មានសម្ងាត់ដែលទាក់ទងនឹងសកម្មភាពធុរកិច្ចរបស់បុគ្គល គឺព័ត៌មានទាំងឡាយដែលការបែកធ្លាយអាចធ្វើឱ្យមានការខូចខាតធ្ងន់ធ្ងរដល់ការធ្វើធុរកិច្ចរបស់បុគ្គលនោះ។ ព័ត៌មានសម្ងាត់ដែលទាក់ទងនឹងសកម្មភាពធុរកិច្ចរបស់បុគ្គលរួមមាន៖

- ព័ត៌មានបច្ចេកទេសឬហិរញ្ញវត្ថុពាក់ព័ន្ធរបស់បុគ្គលនោះ
- ការវាយតម្លៃថ្លៃដើម
- ការសម្ងាត់នៃដំណើរការផលិត
- ប្រភពផ្គត់ផ្គង់វត្ថុធាតុដើម
- បរិមាណនៃការផលិតនិងលក់ចេញ
- ទំហំកាន់កាប់ទីផ្សារ
- បញ្ជីអតិថិជននិងបញ្ជីអ្នកចែកចាយបន្ត
- ផែនការទីផ្សារ
- ព័ត៌មានពាក់ព័ន្ធនឹងថ្លៃដើម ថ្លៃលក់ និងយុទ្ធសាស្ត្រនៃការលក់។

ព័ត៌មានសម្ងាត់ដែលទាក់ទងនឹងអត្តសញ្ញាណរបស់បុគ្គលរាយការណ៍រួមមាន៖

- ឈ្មោះ អាសយដ្ឋាន ទីកន្លែងកំណើត ឬគណនីក្នុងប្រព័ន្ធទំនាក់ទំនងសង្គមរបស់បុគ្គលរាយការណ៍

- ឈ្មោះ អាសយដ្ឋាន ទីកន្លែងកំណើត ឬគណនីក្នុងប្រព័ន្ធទំនាក់ទំនងសង្គមរបស់សហព័ទ្ធ ឪពុក ម្ដាយ កូន ឬបងប្អូនបង្កើតរបស់បុគ្គលរាយការណ៍
- រូបភាពឬសំឡេងរបស់បុគ្គលរាយការណ៍
- រូបភាពរបស់សហព័ទ្ធ ឪពុក ម្ដាយ កូន ឬបងប្អូនបង្កើតរបស់បុគ្គលរាយការណ៍។

រាល់អំពើធ្វើឱ្យបែកធ្លាយនូវព័ត៌មានដែលមានចរិតលក្ខណៈជាការសម្ងាត់ត្រូវបានហាមឃាត់ លើកលែងតែបញ្ញត្តិនៃមាត្រា២៣នៃច្បាប់នេះ។

**មាត្រា២៣ .-**

ក្នុងអំឡុងពេលស៊ើបអង្កេត មន្ត្រីស៊ើបអង្កេតអាចលាតត្រដាងរាល់ព័ត៌មានដែលមានចរិតលក្ខណៈជាការសម្ងាត់បានតែក្នុងករណី៖

១- ចាំបាច់ក្នុងការបំពេញតួនាទីរបស់ខ្លួនស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ។

២- ត្រូវបានអនុញ្ញាតដោយច្បាប់ផ្សេងទៀត។

៣- សម្រួលដល់ភ្នាក់ងាររាជរដ្ឋាភិបាល ឬភ្នាក់ងាររដ្ឋាភិបាលបរទេសក្នុងការបំពេញតួនាទីនិងភារកិច្ចរបស់ខ្លួនដោយត្រូវទទួលបានការអនុញ្ញាតពីប្រធានគ.ប.ក.។

៤- ចាំបាច់ក្នុងការប្រើប្រាស់សិទ្ធិក្នុងការបង្ហាញភស្តុតាងដើម្បីការពារខ្លួន។

**មាត្រា២៤ .-**

ក្នុងដំណាក់កាលស៊ើបអង្កេត ប្រសិនបើមន្ត្រីស៊ើបអង្កេតយល់ឃើញថាចាំបាច់ត្រូវចេញវិធានការផ្អាកជាបណ្ដោះអាសន្ន មន្ត្រីស៊ើបអង្កេតត្រូវស្នើសុំទៅគ.ប.ក. ឱ្យចេញវិធានការផ្អាកជាបណ្ដោះអាសន្នដោយតម្រូវឱ្យបុគ្គលណាមួយ ដែលជាកម្មវត្ថុនៃវិធានការផ្អាកជាបណ្ដោះអាសន្នដូចខាងក្រោមដើម្បី៖

១- ផ្អាកអានុភាពនិង/ឬបញ្ឈប់សកម្មភាពនៃការព្រមព្រៀងណាមួយដែលពាក់ព័ន្ធនឹងការបំពានមាត្រា៧ មាត្រា៨ មាត្រា៩ និងមាត្រា១១នៃច្បាប់នេះ។

២- បញ្ឈប់អំពើណាមួយដែលពាក់ព័ន្ធនឹងការបំពានមាត្រា៧ មាត្រា៨ មាត្រា៩ និងមាត្រា១១នៃច្បាប់នេះ។

៣- ធ្វើសកម្មភាពណាមួយឬមិនឱ្យធ្វើសកម្មភាពណាមួយ។

**មាត្រា២៥ .-**

គ.ប.ក.មានសមត្ថកិច្ចសម្រេចឱ្យមានការដោះស្រាយតាមការចរចាដែលស្នើឡើងដោយមន្ត្រីស៊ើបអង្កេត ហើយសេចក្ដីសម្រេចនេះត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈ។ ការដោះស្រាយតាមការចរចានេះ ត្រូវធ្វើឡើងដោយតម្លាភាព គណនេយ្យភាព និងសុចរិតភាព។

លក្ខខណ្ឌនិងនីតិវិធីនៃការដោះស្រាយនេះត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម។

## ជំពូកទី៥

## វិធានការផ្អាកជាបណ្ដោះអាសន្ននិងសេចក្ដីសម្រេចរបស់គ.ប.ក.

**មាត្រា២៦ .-**

គ.ប.ក.មានសមត្ថកិច្ច៖

ក. ចេញវិធានការផ្អាកជាបណ្ដោះអាសន្ន និង/ឬសេចក្ដីសម្រេច
ខ. ចេញការកំណត់ទណ្ឌកម្មរដ្ឋបាល និង/ឬ
គ. ដាក់ពិន័យជាប្រាក់។

**មាត្រា២៧ ._**

គ.ប.ក.អាចចេញវិធានការផ្អាកជាបណ្ដោះអាសន្នដូចខាងក្រោម៖

១. តាមការស្នើរបស់មន្ត្រីស៊ើបអង្កេតដែលមានមូលហេតុសមស្របអាចឱ្យជឿជាក់បានថាមាត្រា៧ មាត្រា៨ មាត្រា៩ និងមាត្រា១១នៃច្បាប់នេះត្រូវបានបំពានឬអាចត្រូវបានបំពាន ហើយគ.ប.ក.យល់ឃើញថាចាំបាច់ក្នុងការចេញវិធានការផ្អាកជាបណ្ដោះអាសន្នដូចមានចែងនៅក្នុងមាត្រា២៤នៃច្បាប់នេះ ដើម្បីដោះស្រាយបញ្ហាបន្ទាន់ក្នុងគោលបំណង៖

ក. ទប់ស្កាត់ព្យសនកម្មដែលមានលក្ខណៈធ្ងន់ធ្ងរ និង/ឬមិនអាចស្ដារឡើងវិញបានដល់សេដ្ឋកិច្ច ឬដល់បុគ្គលណាមួយ ឬ
ខ. ការពារផលប្រយោជន៍សាធារណៈក្នុងស្ថានភាពអាសន្ន។

២. វិធានការផ្អាកជាបណ្ដោះអាសន្នរបស់គ.ប.ក. ដែលមានចែងនៅក្នុងកថាខណ្ឌទី១នៃមាត្រានេះ អាចតម្រូវឱ្យបុគ្គលណាមួយ៖

ក. ផ្អាកអានុភាពនៃការព្រមព្រៀងឬសកម្មភាពណាមួយដែលសង្ស័យថាបំពានមាត្រា៧ មាត្រា៨ មាត្រា៩ និងមាត្រា១១នៃច្បាប់នេះ។
ខ. ធ្វើសកម្មភាពណាមួយឬមិនឱ្យធ្វើសកម្មភាពណាមួយ ប៉ុន្តែមិនតម្រូវឱ្យមានការបង់ប្រាក់ឡើយ។

៣. គ.ប.ក.អាចដកវិធានការផ្អាកជាបណ្ដោះអាសន្នដែលមានចែងក្នុងកថាខណ្ឌទី១នៃមាត្រានេះវិញនៅពេលណាក៏បាន ដោយមានមូលហេតុសមស្របដែលអាចទទួលយកបាន។

៤. វិធានការផ្អាកជាបណ្ដោះអាសន្នទាំងឡាយដែលមានចែងក្នុងកថាខណ្ឌទី១នៃមាត្រានេះ ត្រូវអស់អានុភាព៖

ក. នៅពេលវិធានការផ្អាកជាបណ្ដោះអាសន្នត្រូវបានដកចេញក្រោមកថាខណ្ឌទី៣នៃមាត្រានេះ ឬ
ខ. នៅពេលគ.ប.ក.ចេញសេចក្ដីសម្រេចលើករណីនោះ ឬ
គ. ក្នុងរយៈពេល១(មួយ)ឆ្នាំ ចាប់ពីថ្ងៃដែលចេញវិធានការផ្អាកជាបណ្ដោះអាសន្ននិងអាចចេញសាជាថ្មីទៀតបាន ដោយមានមូលហេតុសមស្រប។

**មាត្រា២៨ ._**

ក្រោយទទួលបានសំណើពីមន្ត្រីស៊ើបអង្កេតនៅពេលបញ្ចប់ការស៊ើបអង្កេត គ.ប.ក.អាចចេញសេចក្ដីសម្រេចទៅកាន់បុគ្គលណាមួយអំពីការបំពានច្បាប់នេះដោយយោងតាមលក្ខខណ្ឌដូចខាងក្រោម៖

ក. សេចក្ដីសម្រេចត្រូវធ្វើឡើងសម្រាប់តែបុគ្គលណាមួយដែលពាក់ព័ន្ធ ហើយសេចក្ដីសម្រេចទាំងនោះត្រូវផ្សព្វផ្សាយជាសាធារណៈ។
ខ. សេចក្ដីសម្រេចត្រូវបញ្ជាក់៖
- រយៈពេលឱ្យបំពេញលក្ខខណ្ឌតាមសេចក្ដីសម្រេច
- កាលបរិច្ឆេទដែលសេចក្ដីសម្រេចត្រូវផុតកំណត់។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

សេចក្ដីសម្រេចត្រូវបញ្ជាក់ចំណុច ដូចខាងក្រោម៖

ក- អំណាះអំណាងរបស់គ.ប.ក.បង្ហាញថាមាត្រាណាមួយនៃច្បាប់នេះត្រូវបានបំពាន។

ខ- ឈ្មោះឬនាមករណ៍ និងអាសយដ្ឋានរបស់ភាគី និង/ឬតំណាងស្របច្បាប់របស់ភាគី។

គ- សេចក្ដីបញ្ជាក់អំពីកាលបរិច្ឆេទនៃការបង់ប្រាក់ផាកពិន័យ និងសេចក្ដីលំអិតពាក់ព័ន្ធដល់ការបង់ប្រាក់ផាកពិន័យដូចមានចែងក្នុងមាត្រា៣៥នៃច្បាប់នេះ។

ឃ- សេចក្ដីបញ្ជាក់លំអិតពាក់ព័ន្ធដល់វិធានការផ្សេងៗដូចមានចែងក្នុងមាត្រា៣៧នៃច្បាប់នេះ។

ង- ហេតុផលដែលគ.ប.ក.សម្រេចចេញសេចក្ដីសម្រេច។

គ.ប.ក.អាចចេញសេចក្ដីសម្រេចតម្រូវឱ្យចាត់វិធានការផ្សេងៗទៀត ដែលគ.ប.ក.យល់ឃើញថាចាំបាច់ក្នុងការកែលម្អការអនុវត្តសកម្មភាពប្រកួតប្រជែងបំពានច្បាប់។

**មាត្រា២៩ .-**

បែបបទនិងនីតិវិធីនៃការចេញវិធានការផ្អាកជាបណ្ដោះអាសន្ននិង/ឬសេចក្ដីសម្រេច ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម។

**មាត្រា៣០ .-**

បុគ្គលណាមួយដែលមិនសុខចិត្តនឹងវិធានការផ្អាកជាបណ្ដោះអាសន្ននិង/ឬសេចក្ដីសម្រេចរបស់គ.ប.ក. អាចប្ដឹងតវ៉ាទៅគ.ប.ក. ឱ្យពិនិត្យនិងសម្រេចឡើងវិញចំពោះវិធានការផ្អាកជាបណ្ដោះអាសន្ននិង/ឬសេចក្ដីសម្រេចទាំងនេះ ក្នុងរយៈពេល១៥(ដប់ប្រាំ)ថ្ងៃ ដោយគិតចាប់ពីថ្ងៃទទួលបានសេចក្ដីជូនដំណឹងអំពីវិធានការផ្អាកជាបណ្ដោះអាសន្ននិង/ឬសេចក្ដីសម្រេចនោះ។ គ.ប.ក.អាចសម្រេចបដិសេធមិនធ្វើការពិចារណាចំពោះបណ្ដឹងតវ៉ាទាំងនោះ ដោយមានសំអាងហេតុ។

ក្នុងករណីគ.ប.ក.បដិសេធលើបណ្ដឹងស្នើសុំឱ្យពិនិត្យឡើងវិញលើវិធានការផ្អាកជាបណ្ដោះអាសន្ននិង/ឬសេចក្ដីសម្រេចរបស់គ.ប.ក. បុគ្គលនោះអាចប្ដឹងតវ៉ាទៅតុលាការមានសមត្ថកិច្ចបានក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ ដោយគិតចាប់ពីថ្ងៃទទួលបានសេចក្ដីជូនដំណឹងអំពីការបដិសេធនោះ។

**មាត្រា៣១ .-**

វិធានការផ្អាកជាបណ្ដោះអាសន្ននិង/ឬសេចក្ដីសម្រេចរបស់គ.ប.ក. អាចជាកម្មវត្ថុនៃការប្ដឹងតវ៉ាទៅតុលាការមានសមត្ថកិច្ចបានក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ បន្ទាប់ពីថ្ងៃទទួលបានសេចក្ដីជូនដំណឹងអំពីវិធានការផ្អាកជាបណ្ដោះអាសន្ននិង/ឬសេចក្ដីសម្រេចនោះ។

**មាត្រា៣២ .-**

វិធានការផ្អាកជាបណ្ដោះអាសន្នត្រូវមានអានុភាពអនុវត្តភ្លាម ទោះបីមានបណ្ដឹងតវ៉ាក៏ដោយ។

សេចក្ដីសម្រេចត្រូវមានអានុភាពអនុវត្តនិងមិនអាចជាកម្មវត្ថុនៃការប្ដឹងតវ៉ាទៀតឡើយក្នុងករណីដូចខាងក្រោម៖

ក- រយៈពេលសម្រាប់ការប្ដឹងតវ៉ាត្រូវបានផុតកំណត់ ឬ

ខ- ពេលតុលាការមានសមត្ថកិច្ចចុងក្រោយបានបដិសេធការប្ដឹងតវ៉ា។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

**មាត្រា៣៣ .-**

ក្នុងករណីបុគ្គលបំពានច្បាប់មិនអនុវត្តវិធានការផ្អាកជាបណ្តោះអាសន្ននិង/ឬសេចក្តីសម្រេច គ.ប.ក. ត្រូវស្នើសុំជំនួយពីអាជ្ញាធរតុលាការមានសមត្ថកិច្ចដើម្បីអនុវត្តវិធានការផ្អាកជាបណ្តោះអាសន្ននិង/ឬសេចក្តីសម្រេចរបស់គ.ប.ក.។

## ជំពូកទី៦
## ទោសប្បញ្ញត្តិ

**មាត្រា៣៤ .-**

ទណ្ឌកម្មនៅក្នុងច្បាប់នេះរួមមាន ការព្រមានជាលាយលក្ខណ៍អក្សរ ការព្យួរ ការដកហូត ឬការលុបចោលវិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីពាណិជ្ជកម្ម អាជ្ញាបណ្ណ ឬលិខិតអនុញ្ញាតប្រកបអាជីវកម្ម-សេវាកម្ម ការផាកពិន័យជាប្រាក់ ទោសពិន័យជាប្រាក់ និងទោសដាក់ពន្ធនាគារ។

ការព្រមានជាលាយលក្ខណ៍អក្សរ និងការផាកពិន័យជាប្រាក់ ជាសមត្ថកិច្ចរបស់គ.ប.ក.។

គ.ប.ក.ស្នើសុំទៅក្រសួង ស្ថាប័នសាមីចាត់វិធានការ ព្យួរ ដកហូត ឬលុបចោលវិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីពាណិជ្ជកម្ម អាជ្ញាបណ្ណ ឬលិខិតអនុញ្ញាតប្រកបអាជីវកម្ម-សេវាកម្ម។

ក្នុងករណីមិនព្រមបង់ប្រាក់ផាកពិន័យ គ.ប.ក.ប្តឹងទាមទារប្រាក់ផាកពិន័យទៅតុលាការមានសមត្ថកិច្ច។

រាល់ប្រាក់ផាកពិន័យទាំងឡាយដែលមានចែងក្នុងច្បាប់នេះ ត្រូវបង់ចូលថវិកាជាតិស្របតាមវិធានហិរញ្ញវត្ថុសាធារណៈជាធរមាន។

នីតិវិធីនៃការផាកពិន័យជាប្រាក់ ដូចមានចែងនៅក្នុងបទប្បញ្ញត្តិច្បាប់នេះ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មនិងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

នីតិវិធីនៃការបង់ប្រាក់ផាកពិន័យ ការគ្រប់គ្រងបង្កាន់ដៃបង់ប្រាក់ផាកពិន័យ និងការចាត់ចែងប្រាក់ចំណូលដែលបានមកពីការផាកពិន័យ ដូចមានចែងនៅក្នុងបទប្បញ្ញត្តិច្បាប់នេះ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មនិងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា៣៥ .-**

បុគ្គលដែលបំពានមាត្រា៨ មាត្រា៩ និងមាត្រា១១នៃច្បាប់នេះ ត្រូវទទួលការព្រមានជាលាយលក្ខណ៍អក្សរ និងផាកពិន័យជាប្រាក់ពី៣% ទៅ១០% ដោយគ.ប.ក. នៃផលរបរសរុបរបស់បុគ្គលដែលទទួលបានក្នុងអំឡុងពេលដែលការបំពានច្បាប់បានកើតឡើង និងមិនលើសពីរយៈពេល៣(បី)ឆ្នាំ។

ក្នុងករណីទទួលនូវការព្រមានជាលាយលក្ខណ៍អក្សរនិងការផាកពិន័យជាប្រាក់ម្តងរួចមកហើយ នៅតែបន្តប្រព្រឹត្តល្មើសដូចកថាខណ្ឌទី១នៃមាត្រានេះ ត្រូវព្យួរ ដកហូត ឬលុបចោលវិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីពាណិជ្ជកម្ម អាជ្ញាបណ្ណ ឬលិខិតអនុញ្ញាតប្រកបអាជីវកម្ម-សេវាកម្ម។

**មាត្រា៣៦ .-**

បទប្បញ្ញត្តិនៃជំពូកទោល(បទប្បញ្ញត្តិទូទៅ)នៃមាតិកាទី១(បទប្បញ្ញត្តិទូទៅ) ជំពូកទោល(ការបង្ខំដល់រូបកាយ)នៃគន្ថីទី៨នៃក្រមនីតិវិធីព្រហ្មទណ្ឌ ត្រូវយកមកអនុវត្តក្នុងករណីដែលសេចក្តីសម្រេចអំពីការផាកពិន័យបានចូលជាស្ថាពរ។

**មាត្រា៣៧.-**

គ.ប.ក. អាចចេញវិធានការបន្ថែមលើអំពើរាំង រឹតត្បិត ឬបង្ខូចដល់ការប្រកួតប្រជែងដូចខាងក្រោម៖

១- ហាមឃាត់បុគ្គលដែលបំពានច្បាប់នេះ មិនឱ្យបន្តសកម្មភាពបំពានច្បាប់បន្តទៅទៀត។

២- តម្រូវឱ្យបុគ្គលដែលបំពានច្បាប់នេះ លក់ចេញនូវភាគហ៊ុនឬផ្នែកខ្លះនៃធុរកិច្ចរបស់ខ្លួនទៅឱ្យបុគ្គលផ្សេងទៀតក្នុងតម្លៃទីផ្សារ ដើម្បីធានាឱ្យមានការប្រកួតប្រជែងនៅក្នុងទីផ្សារ។

៣- តម្រូវឱ្យបុគ្គលដែលបំពានច្បាប់នេះ ចែករំលែកអាជ្ញាបណ្ណឬកម្មសិទ្ធិបញ្ញារបស់ខ្លួនដែលពាក់ព័ន្ធដល់ការបំពានច្បាប់ក្នុងគោលដៅស្តារ ថែរក្សា ឬការពារទីផ្សារប្រកួតប្រជែង។

៤- តម្រូវឱ្យបុគ្គលដែលបំពានច្បាប់នេះ ហើយបានបង្កការខូចខាតដល់បុគ្គលដទៃទៀតសងសំណងខូចខាតទៅបុគ្គលទាំងនោះស្មើនឹងចំនួនទឹកប្រាក់ដែលបានខូចខាតដោយសារការបំពានច្បាប់នេះ។

៥- តម្រូវឱ្យបុគ្គលដែលបំពានច្បាប់នេះ សងប្រាក់ចំណេញដែលបានមកពីអំពើបំពានច្បាប់ជូនជនរងគ្រោះទាំងឡាយណា ដែលអាចកំណត់អត្តសញ្ញាណបានថាពិតជារងគ្រោះដោយសកម្មភាពធុរកិច្ចដែលបំពានច្បាប់នោះមែន។

៦- តម្រូវឱ្យផ្តល់ប្រាក់ចំណេញ ដែលទទួលបានមកពីអំពើបំពានច្បាប់ ជូនអង្គការសង្គមទាំងឡាយដែលតំណាងឱ្យផលប្រយោជន៍ជនរងគ្រោះពីការបំពានច្បាប់ ក្នុងករណីដែលរកមិនឃើញអត្តសញ្ញាណជនរងគ្រោះច្បាស់លាស់ឬមិនអាចបែងចែកជាទឹកប្រាក់ជាក់លាក់ដល់ជនរងគ្រោះម្នាក់ៗបាន។

៧- តម្រូវឱ្យបុគ្គលដែលបំពានច្បាប់នេះ ផ្តល់របាយការណ៍ដែលបញ្ជាក់អំពីការអនុវត្តសេចក្តីសម្រេចរបស់គ.ប.ក.។

៨- តម្រូវឱ្យបុគ្គលដែលបំពានច្បាប់នេះ បង់ថ្លៃសេវាឱ្យអ្នកជំនាញដែលបានតែងតាំងដើម្បីផ្តល់យោបល់ជូនគ.ប.ក.។

៩- ចាត់វិធានការចាំបាច់នានាដើម្បីស្តារការប្រកួតប្រជែងឡើងវិញ។

**មាត្រា៣៨.-**

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ខែ ទៅ២(ពីរ)ឆ្នាំ និងពិន័យជាប្រាក់ពី៥ ០០០ ០០០(ប្រាំលាន)រៀល ទៅ១០០ ០០០ ០០០(មួយរយលាន)រៀល ចំពោះរូបវន្តបុគ្គលដែលចូលរួមក្នុងការព្រមព្រៀងខ្សែដេក ដូចមានចែងក្នុងមាត្រា៧នៃច្បាប់នេះ។

ត្រូវពិន័យជាប្រាក់ពី១០០ ០០០ ០០០(មួយរយលាន)រៀល ទៅ២ ០០០ ០០០ ០០០(ពីរពាន់លាន)រៀល ចំពោះនីតិបុគ្គលដែលចូលរួមក្នុងការព្រមព្រៀងខ្សែដេក ដូចមានចែងក្នុងមាត្រា៧នៃច្បាប់នេះ។

**មាត្រា៣៩.-**

ការអនុវត្តបទប្បញ្ញត្តិនៃជំពូកទី៦(ទោសប្បញ្ញត្តិ)នៃច្បាប់នេះ មិនរារាំងការអនុវត្តច្បាប់ព្រហ្មទណ្ឌផ្សេងទៀត ក្នុងករណីដែលអំពើបំពានលើបទប្បញ្ញត្តិដែលមានចែងក្នុងច្បាប់នេះជាបទល្មើស ដែលបានបញ្ញត្តក្នុងច្បាប់ព្រហ្មទណ្ឌផ្សេងទៀត។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

## ជំពូកទី៧
## អវសានប្បញ្ញត្តិ

**មាត្រា៤០ ._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៤១ ._**

ច្បាប់នេះត្រូវប្រកាសជាការប្រញាប់។

ថ្ងៃ *អង្គារ ១៤រោច* ខែ*ភទ្របទ* ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី *០៥* ខែ *តុលា* ឆ្នាំ២០២១

*នរោត្តម សីហមុនី*

**នរោត្តម សីហមុនី**

*នស/រកម/១០២១/០១៥*

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ប៉ាន សូរស័ក្តិ**